គម្រោង PRIP សាងសង់កំណាត់ផ្លូវ១៨គីឡូម៉ែត្រឡើងនៅស្រុករវៀងខេត្តព្រះវិហារ

ស្រុករវៀង-ព្រះវិហារ ៖ កំណាត់ផ្លូវ១៨គីឡូម៉ែត្រនៃផ្លូវលេខ២១៣ ក្នុងស្រុករវៀង ខេត្តព្រះវិហារ បានបើកការដ្ឋានសាងសង់ចាក់កៅស៊ូ កាលពីថ្ងៃទី២១ខែធ្នូឆ្នាំ២០១០ ក្រោមអធិបតីភាពលោកត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការ ដឹកជញ្ជូន ។ នេះជាគម្រោងហេដ្ឋារចនាសម្ព័ន្ធខេត្ត និងជនបទដែលហៅកាត់ថា (PRIP) ស្ថិតក្រោមលុយឥណទានរបស់ធនាគារពិភពលោក រួមនឹងលុយបដិភាគរបស់រដ្ឋាភិបាល១០ភាគរយ ។

លោកត្រាំ អ៊ីវតឹក បានមានប្រសាសន៍ថា ផ្លូវនេះពីមុនជាផ្លូវដីក្រហមក្រហូង ពិបាកធ្វើដំណើរណាស់ ។ ឥឡូវយើងបានប្រែក្លាយវាឱ្យទៅជាផ្លូវចាក់កៅស៊ូកែលម្អពង្រីកតួផ្លូវឱ្យធំ នឹងកែលម្អជួសជុលស្ពានតូចធំឱ្យបានស្អាតទូលាយឡើងវិញ ។ ការសាងសង់ផ្លូវនេះស្ថិតក្នុងឃុទ្ធសាស្ត្រមួយមានទិសដៅកាត់បន្ថយភាពក្រីក្រ និងទុក្ខលំបាកវេទនារបស់ប្រជាជនតាមជនបទ។

លោកលឹម ស៊ីដេនីន រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូនបានលើកឡើងថា គម្រោង PRIP នេះមានតាំងពីឆ្នាំ២០០៤មកម្ល៉េះដោយមានក្រសួងសាធារណការនិងក្រសួងអភិវឌ្ឍន៍ជនបទជាអ្នកអនុវត្តធ្វើយ៉ាងណាឱ្យមានការភ្ជាប់រវាងទីក្រុង ទីប្រជុំជន និងជនបទដាច់ស្រយាល ។

កំណាត់ផ្លូវលេខ២១៣ដែលមានប្រវែងជាង៧៩គីឡូម៉ែត្រកាត់តាមស្រុករវៀងដែលមានប្រជាជនជិត៤ម៉ឺននាក់ ស្រុកឆែប មានប្រជាជនជាច្រើនម៉ឺននាក់ទៀត ។ វាជាកំណាត់ផ្លូវបម្រើឱ្យការដឹកជញ្ជូនកសិផលយ៉ាងសម្បើមពិសេសផលស្រូវ និងកសិឧស្សាហកម្មជាច្រើនទៀតដែលប្រជាជននៅទីនេះផលិតបានលក់មកកាន់ទីផ្សារ ។

លោកលឹម ស៊ីដេនីន បានឱ្យដឹងទៀតថាកំណាត់ផ្លូវដែលចាប់ផ្តើមសាងសង់នាពេលនេះត្រូវលើកកម្ពស់តួផ្ទប់ បន្ថែមនិងក្រាលកៅស៊ូពីរជាន់មានទទឹងផ្ទប់៦ម៉ែត្រ និងទុកចិញ្ចើមផ្ទប់សងខាង២ម៉ែត្រព្រមទាំងមានការសាងសង់ស្ពានតូចធំលូជាច្រើនកន្លែងទៀត ។ តម្លៃនៃការសាងសង់កំណាត់ផ្លូវនេះមានប្រមាណជាង៣លានដុល្លារអាមេរិក ។

គួរបញ្ជាក់ដែរថា គម្រោង PRIP ជាគម្រោងរបស់ធនាគារពិភពលោកសម្រាប់អនុវត្តនៅលើខេត្ត៤ គឺខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប និងខេត្តឧត្តមានជ័យដែលមានទឹកប្រាក់សរុប២០លានដុល្លារអាមេរិក និងលុយបដិភាគរដ្ឋាភិបាល ៣លានដុល្លារអាមេរិក គម្រោងនេះនឹងត្រូវបញ្ចប់ក្នុងដំណាច់ឆ្នាំ២០១១ខាងមុខនេះ ។

មូល សម្ប្តិ

មន្ត្រីសាធារណការ បានទៅចូលរួមបើកសម្ពោធការដ្ឋានសាងសង់ផ្លូវចាក់កៅស៊ូ ប្រវែង១៨គីឡូម៉ែត្រ ជូនដល់ប្រជាជនស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃ២១ ធ្នូ ២០១០ (រូបថត:មូល សម្ប្តិ)

ផ្លូវពង្រាប-លូសពង្រីក ក្រៀមចាក់កៅស៊ូ លើកំណាត់ផ្លូវលេខ២១៣ ពីស្រុករវៀង ទៅកាន់ស្រុកឆែប ខេត្តព្រះវិហារ សម្រួលការធ្វើដំណើររបស់ប្រជាជន